ក្រសួងពាណិជ្ជកម្ម
លេខ ១៣៣៦ ព.ណ.សសក

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម សូមជូនដំណឹងដល់សាធារណជនមេត្តាជ្រាបថា ប្រព័ន្ធតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា កំណែ ២.០ (SETFO 2.0) ត្រូវបានតភ្ជាប់ជាមួយនឹង ធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់ការទូទាត់កម្រៃសេវាសាធារណៈតាមប្រព័ន្ធអនឡាញ ចាប់ពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៥ តទៅ។

ការតភ្ជាប់ជាមួយ ធនាគារ អេស៊ីលីដា ភីអិលស៊ី នេះ នឹងផ្តល់ភាពងាយស្រួល និងជម្រើសកាន់តែច្រើនដល់អ្នកប្រើប្រាស់ក្នុងការទូទាត់កម្រៃសេវាសាធារណៈរបស់ប្រព័ន្ធ SETFO 2.0 ដោយពុំចាំបាច់អញ្ជើញមកទូទាត់ប្រាក់ដោយផ្ទាល់នៅបញ្ជរបង់ប្រាក់ក្រសួងពាណិជ្ជកម្មទៀតឡើយ។

សម្រាប់ព័ត៌មានពាក់ព័ន្ធនឹងនីតិវិធីប្រើប្រាស់ និងកម្រៃសេវាសាធារណៈរបស់ប្រព័ន្ធ SETFO 2.0 សូមទាក់ទងមកកាន់មន្ត្រីនៃការិយាល័យតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា នៃក្រសួងពាណិជ្ជកម្ម តាមរយៈគេហទំព័រ www.setfo.moc.gov.kh ទូរសព្ទលេខ 089 510 600 ឬ Hotline: 1266 ឬអ៊ីមែល setfo@moc.gov.kh។

ថ្ងៃសុក្រ ៦កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៥

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម